# សេចក្តីប្រកាស អំពីវិជ្ជាស្ថានសិក្សាតាមអ៊ិនធ័រណិតនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា

## រាត្រីផ្តល់ព័ត៌មាន • **ថ្ងៃពុធ ទី៨ ខែឧសភា ឆ្នាំ២០១៣ • ៦:០០-៧:៣០ យប់**

នៅមជ្ឍមណ្ឌលអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា

440 N. Broad Street, Philadelphia, PA • បន្ទប់លេខ ១០៧៥ (ជាន់ទី១)

ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣

ជូនចំពោះមាតាបិតា/អាណាព្យាបាលះ

ខ្ញុំបានសរសេរទៅកាន់លោកអ្នកនៅថ្ងៃនេះ គឺដើម្បីចែករំលែកព័ត៌មានដែលគួរឱ្យរំភើបសម្រាប់ឆ្នាំសិក្សានាពេលខាងមុខ។ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា មានមោទនភាពដើម្បីប្រកាសពីការពង្រីកកម្មវិធីសិក្សា ដោយរួមបញ្ចូលឱកាសសិក្សាពេញម៉ោង តាមអ៊ិនធ័រណិត សម្រាប់សិស្សានុសិស្ស ថ្នាក់ទី៦ ដល់ថ្នាក់ទី១២ ណាដែលត្រូវការពេលវេលាដែលអាចផ្លាស់ប្តូរបាន ប៉ុន្តែចង់បានជំនួយជាច្រើនដែលក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ាផ្តល់ឲ្យ។

ចំពោះក្រុមគ្រួសារដែលបច្ចុប្បន្ននេះមានកូនរៀននៅសាលាឆាទ័រ យើងខ្ញុំស្វាគមន៍ និងសូមឲ្យលោកអ្នកពិចារណាដើម្បីត្រឡប់មកក្រសួងអប់រំនៃទីក្រុង្ហ្វីឡាដែលហ្វ្យ៉ាវិញ តាមរយៈការចូលរួមជាមួយវិជ្ជាស្ថានសិក្សាតាមអ៊ិនធ័រណិតនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា (PVA) ថ្មីនេះ។

វិជ្ជាស្ថានសិក្សាតាមអ៊ិនធ័រណិតនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា គឺជាសាលារៀនដោយឥតបង់ថ្លៃ សម្រាប់សិស្សដែលបានរៀនចប់ថ្នាក់ទី៥ដោយជោគជ័យ ហើយចង់បន្តការសិក្សាដែលមានគុណភាពតាមអ៊ិនធ័រណិត សម្រាប់ថ្នាក់ទី៦ ដល់ថ្នាក់ទី១២។ សិស្សានុសិស្សនឹងទទួលបាន កុំព្យូទ័រយួរដៃមួយ ការប្រើអ៊ិនធ័រណិតដែលមានល្បឿនលឿន និងកម្មវិធីសិក្សាដែលទទួលស្គាល់ដោយក្រសួងអប់រំនៃរដ្ឋផិនស៊ីវេនីញ៉ា បង្រៀនដោយគ្រូដែលមានសមត្ថភាពខ្ពស់ មានវិញ្ញាបនបត្រពីរដ្ឋ។ លើសពីនេះទៀត សិស្សានុសិស្សអាចទៅ មណ្ឌលសិក្សាដែលអ្នកអាចមកគ្រប់ពេល (drop-in learning centers) សម្រាប់ការផ្តល់ជំនួយផ្នែកអប់រំ និងឱកាសចូលរួមក្នុងសកម្មភាពក្រៅម៉ោងសិក្សា និង កីឡា របស់ក្រសួង។

សិស្សានុសិស្សដែលបានបញ្ចប់ការសិក្សាជាមួយ PVA នឹងទទួលសញ្ញាប័ត្រទុតិយភូមិ ពីក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា។

នៅក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា យើងយល់ពីលក្ខណៈខុសៗគ្នានៃវិធីរៀនសូត្ររបស់សិស្ស។ សិស្សខ្លះរៀនលឿននៅក្នុងការរៀបចំតាមរបៀបសាលាធម្មតាក្នុងពេលជាមួយគ្នានេះ មានសិស្សដទៃទៀតរៀនបានលឿនជាង តាមរយៈការសិក្សាដោយខ្លួនឯង។ ការសហការជាមួយគ្នាជាក្រុម ខ្ញុំមានជំនឿថា យើងអាចធ្វើឲ្យបទពិសោធន៍នៃការរៀនសូត្ររបស់សិស្សម្នាក់ៗ បានទទួលជោគជ័យ និងទទួលលទ្ធផលជាទីគប្បិចិត្ត ទោះបីជារៀនតាមរបៀបសាលាធម្មតា ឬ តាមសាលាថ្មីរបស់ក្រសួង – គឺ វិជ្ជាស្ថានសិក្សាតាមអ៊ិនធ័រណិតនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា នេះក៏ដោយ។

ខ្ញុំសូមអញ្ជើញលោកអ្នកមកស្វែងយល់បន្ថែមទៀត អំពី PVA នៅក្នុងរាត្រីផ្តល់ព័ត៌មាន សម្រាប់មាតាបិតា និងសិស្សានុសិស្ស នៅ**ថ្ងៃពុធ ទី៨ ខែឧសភា ឆ្នាំ២០១៣ ពីម៉ោង ៦ ដល់ ៧:៣០ យប់ នៅមណ្ឌលអបរំ** 440 N. Broad Street, Philadelphia, PA។ យើងខ្ញុំទន្ទឹងរង់ចាំជួបជាមួយលោកអ្នក នៅក្នុងបន្ទប់លេខ ១០៧៥ (ជាន់ទី១)។

ខ្ញុំបានភ្ជាប់មកជាមួយនូវកូនសៀវភៅ ដើម្បីឲ្យលោកអ្នកបានយល់បន្ថែមទៀត អំពីការអប់រំថ្មីរបស់យើង និងមុខវិទ្យាដែលយើងបង្រៀន។ បើសិនជាលោកអ្នកមានសំណួរអ្វី ឬចង់បានព័ត៌មានបន្ថែមទៀត សូមទូរស័ព្ទមកលេខ ២១៥-៤០០-៨៤៨៤ ឬផ្ញើសំណួរមកយើងខ្ញុំតាមវ៉ិបសៃ **www.philasd.org/language/khmer/help**។

*អញ្ជើញចូលរួម ការបើកឲ្យមើលកន្លែង នៅរដូវផ្ការីក!*

*មកជួបផ្ទាល់៖*

ថ្ងៃពុធ ទី៨ ខែឧសភា ៦-៧:៣០ យប់
Education Center (440 N. Broad Street, Rm. 1075)

ថ្ងៃពុធ ទី១៥ ខែឧសភា ៥:៣០-៧ យប់
Kensington CAPA High School (1901 N. Front St.)

ថ្ងៃពុធ ទី២៩ ខែឧសភា ២-៣:៣០ រសៀល
West Philadelphia High School (4901 Chestnut St.)

ថ្ងៃអង្គារ ទី១១ ខែមិថុនា ៥:៣០-៧ យប់
Northeast High School (1601 Cottman Ave.)

*តាមអ៊ិនធ័រណិត៖*

**ថ្ងៃព្រហស្បតិ៍ ទី២ ខែឧសភា ១-២ រសៀល**
**ថ្ងៃព្រហស្បតិ៍ ទី៦ ខែមិថុនា ១១-១២ ថ្ងៃត្រង់**
**ថ្ងៃពុធ ទី១០ ខែកក្កដា ៧-៨ យប់**
**ថ្ងៃព្រហស្បតិ៍ ទី៨ ខែសីហា ១-២ រសៀល**

ការជួបប្រជុំតាមអ៊ិនធ័រណិត គឺធ្វើឡើងនៅក្នុងបន្ទប់ប្រជុំតាមកុំព្យូទ័រ។ សូមអានអំពីវិជ្ជាស្ថានតាមអ៊ិនធ័រណិត ក្នុងវ៉ិបសៃ http://www.philasd.org/pva ដើម្បីឲ្យដឹងពីវិធីចុះឈ្មោះសុំចូលរៀន។

ដោយសេចក្តីគោរពរាប់អាន

William R. Hite, Jr., Ed.D.
អគ្គនាយក
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា